## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១


**យុវតី តុង មិនា**

*ជាសិស្សថ្នាក់ទី ១០ នៃវិទ្យាល័យព្រះបាទសុរាម្រឹត ខេត្តកំពង់ឆ្នាំង*


**ចំណងជើងកំណាព្យ៖ «អំណានក្នុងបរិបទកូវីដ-១៩ »**

(កំណាព្យបទ ពាក្យប្រាំពីរ)

| | | |
|---|---|---|
| ១. | អំណានជាផ្នែកមួយសំខាន់ | យើងត្រូវប្រកាន់ឱ្យបានខ្ជាប់ |
| | ការអាននេះគឺជាទម្លាប់ | អានឱ្យបានជាប់ជាប្រចាំ។ |
| ២. | ប៉ុន្តែក្នុងឆ្នាំពីរពាន់ម្ភៃ | វីរុសចង្រៃនាំក្ដីក្ដាំ |
| | សម្លាប់មនុស្សលោកជាប្រចាំ | រស់ជាងមួយឆ្នាំសែនវេទនា។ |
| ៣. | សាលាទាំងអស់ត្រូវបានបិទ | ការពារភ័យភិតគ្រប់វេលា |
| | ចំណែកការអានក៏ដូចគ្នា | ដើម្បីការពារដល់លោកា។ |
| ៤. | យើងធ្លាប់អានពេលជួបជុំមិត្ត | រីករាយពេកពិតនៅសាលា |
| | តែពេលនេះត្រូវអានបែបណា | ដើម្បីបង្ការនូវគ្រោះភ័យ។ |
| ៥. | គួរអាននៅផ្ទះគ្រប់អង្គា | បច្ចេកវិទ្យាមានមិនថ្វី |
| | ទូរស័ព្ទយើងមានគ្រប់ៗដៃ | មិនបាច់ព្រួយភ័យក្នុងការអាន។ |
| ៦. | មិនថាព័ត៌មានឬសិក្សា | អានគ្រប់សប្ដាហ៍សុទ្ធតែបាន |
| | កម្មវិធីច្រើនហួសប្រមាណ | មិនពិបាកអាននៅខាងក្រៅ។ |
| ៧. | មានទូរស័ព្ទហើយសូមកុំភ្លេច | ត្រូវចាំជានិច្ចអានសៀវភៅ |
| | អានច្រើនចេះច្រើនពិតត្រឹមត្រូវ | ព្រោះបានតម្រូវចិត្តគ្រប់គ្នា។ |
| ៨. | មិនបាច់ទៅបណ្ណាល័យ | ចេញពីផ្ទះថ្លៃខាតវេលា |
| | នាំឆ្លងជំងឺហើយវេទនា | បច្ចេកវិទ្យាយើងមានស្រាប់។ |
| ៩. | ក្រសួងក៏បានប្រកាសហើយ | សិស្សទាំងឡាយអើយចូរចាំស្ដាប់ |
| | ពាក្យណែនាំលោកដោយត្រងត្រាប់ | ប្រើប្រាស់ទូរស័ព្ទមកសិក្សា។ |
| ១០. | អំណានមានតម្លៃលើសអ្វី | ដល់ជនប្រុសស្រីគ្រប់អាត្មា |
| | អានមានតម្លៃល្អថ្លៃថ្លា | កុំបោះបង់ណាត្រូវខំប្រឹង។ |
| ១១. | ត្រូវអានក៏ដូចជាសិក្សា | សង្ខាតដោយស្មារតីរឹងប៉ឹង |
| | អានមានប្រយោជន៍ផ្ដល់លំនឹង | ជួយរឹតបន្តឹងការសិក្សា៕ |

## ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១

**យុវតី អាន រក្សា**

ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យក្រែក មកពីខេត្តត្បូងឃ្មុំ

**ចំណងជើងកំណាព្យ៖ «អំណានក្នុងសម័យកូវីដ-១៩»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១. សម័យកូវីដយើងនៅផ្ទះ មិនត្រូវខ្ជាយខ្ជះពេលវេលា
គួរអានសៀវភៅក្រេបវិជ្ជា ចំណេះនានាឱ្យថ្កុំថ្កើន។

២. ការអានពិតផ្តល់ចំណេះដឹង ត្រូវខិតខំប្រឹងឱ្យកំណើន
ព្រោះថាបើអានកាន់តែច្រើន ចំណេះទ្វេកើនមិនរបេះ។

៣. តើអានសៀវភៅដើម្បីអ្វី ចម្លើយគឺខ្លីដើម្បីចេះ
គឺអានដើម្បីបំបាត់ស្រេ្តស ពង្រីកចំណេះឱ្យអស្ចារ្យ។

៤. កូវីដនាំទុក្ខនាំកង្វល់ សូមនឹកគិតដល់សៀវភៅណ៎ា
គឺអានដើម្បីស្រាយបញ្ហា បានគ្រប់កិច្ចការយ៉ាងចំណាន។

៥. ការអានពិតជាមានសារៈ ត្រិះរិះរិតក្តយ៉ាងហំហាន
ទើបមានទិវាជាតិអំណាន ទិវាថ្កើងថ្កានស៊ីជម្រៅ។

៦. បើយើងគិតតែលេងទូរស័ព្ទ មិនខំស្វាហាប់អានសៀវភៅ
ប្រាជ្ញាអួរអាប់គិតមិនជ្រៅ នាំឱ្យល្ងង់ខ្លៅខ្សោយបញ្ញា។

៧. បើចង់ស្រាវជ្រាវមិនយល់អ្វី គ្រប់សៀវភៅក្តីអាចប្រើការ
អានក្រេបចំណេះផុសវិចារ ចេញជាផ្លែផ្កាដូចបំណង។

៨. ម្ល៉ោះហើយត្រូវអានជាប្រចាំ ព្រោះវាជាថ្នាំល្អកន្លង
ចៀសឆ្ងាយកូវីដចាកទុក្ខផង រួចផុតសៅហ្មងជាលម្អ។

៩. ឱ!វប្បធម៌នៃអំណាន ជាតិយើងថ្កើងថ្កានល្អបវរ
បណ្តុះទម្លាប់ឱ្យយើងល្អ ជាកេរ្តិ៍តំណតរក្សា។

១០. ឱ!យុវជនទាំងប្រុសស្រី គួរខំឃ្មាតខ្មីឱ្យពិស្តារ
សង្គមជឿនលឿនតម្រូវការ ជនមានប្រាជ្ញាថ្លាឧត្តម៕

**ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ**

**«ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»**

**អបអរសាទរ ទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១**

**យុវតី អេង ស្រីយ៉ា**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យជ្រោះប៊ូស្រា ខេត្តមណ្ឌលគិរី*

**ចំណងជើងកំណាព្យ៖ «អំណានក្នុងសម័យកូវីដ-១៩»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១. មុនពេលកូវីដសិស្សសិក្សា    នៅក្នុងសាលាសព្វវិជ្ជា
បំណិនចំណេះដឹងនានា    ទុកជាមាគ៌ានាំជោគជ័យ។

២. ជំងឺកូវីដចូលមកដល់    វាបានបន្សល់នូវទុក្ខភ័យ
ឆ្លងរីករាលដាលជនគ្រប់វ័យ    ក្មេងចាស់ប្រុសស្រីគ្មានអាណិត។

៣. ក្រសួងប្រកាសបិទសាលា    ផ្អាកការសិក្សាគ្រប់កម្រិត
រួមទាំងគរុសិស្សនិស្សិត    បែកមិត្តជិតស្និទ្ធគ្រប់ៗគ្នា។

៤. សិស្សក៏បន្តស្វ័យសិក្សា    បំពេញកិច្ចការតាមបញ្ជា
រៀនពីចម្ងាយគ្រប់អង្គា    សិស្សមិនរុញរាខំប្រឹងប្រែង។

៥. រៀនតាមទូរស័ព្ទឬហ្វេសបុក    ថតរក្សាទុកពិតជាក់ស្តែង
មេរៀនក្រសួងបានចារបែង    ខំរៀនខ្លួនឯងគ្រប់អាត្មា។

៦. មិនថាសិស្សតូចឬសិស្សធំ    រៀនតាមបណ្តុំក្រៅសាលា
លោកគ្រូអ្នកគ្រូដាក់កិច្ចការ    យកវិញ្ញាសាធ្វើនៅផ្ទះ។

៧. សិស្សបានលំហាត់យកទៅធ្វើ    មិននៅស្ងាក់ស្ទើរប្រឹងជម្នះ
ដកស្រង់ស្រាវជ្រាវមិនឱ្យស្ទះ    រួចហើយរូតរះជូនគ្រូកែ។

៨. អាណាព្យាបាលឪពុកម្តាយ    ចូលរួមខ្វល់ខ្វាយជួយកូនដែរ
រៀនលេខអក្សរភាសាខ្មែរ    ព្យាយាមហូរហែមិនឿយណាយ។

៩. ទោះមិនបានរៀននៅសាលា    តែការសិក្សាពីចម្ងាយ
លោកគ្រូអ្នកគ្រូឪពុកម្តាយ    រួមចិត្តរួមកាយជួយបង្រៀន។

១០. ផ្សព្វផ្សាយអំពីអនាម័យ    ទើបចៀសផុតភ័យកុំបំពាន
ស្អាតទាំងនៅផ្ទះនិងទៅរៀន    ពាក់ម៉ាស់កុំអៀនសុខភាពល្អ។

១១. ទោះបីជំងឺកូរ៉ូណា    តែការសិក្សាពិតបវរ
យកជ័យជម្នះជាបន្ត    ដើម្បីគាំទ្រគ្រឹះវិជ្ជា។

១២. សូមថ្លែងអំណរក្រសួងរដ្ឋ    គាំទ្រម៉ត់ចត់ផ្តល់យុទ្ធនា
ការថៃទាំសុខភាពប្រជា    កូនខ្មែរគ្រប់គ្នាសុខក្សេមក្សាន្ត៕